ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខៈ ២០៣៩ ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបាត់ដំបង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តបាត់ដំបង

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបាត់ដំបងជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តបាត់ដំបងមានរាង ខ្នាត និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោមៈ
- មានរាងពងក្រពើ
- មានទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្តោយ

- ដំបងពណ៌ត្បូងកណ្ដៀង តំណាងឱ្យការៈល្អ មានតេជៈបារមី និងសិទ្ធិអំណាចក្នុងការថែរក្សាការពារកសាងទឹកដីខេត្តបាត់ដំបងឱ្យបានគង់វង្សជារៀងរហូតមក
- ទម្រជើងពានមានលម្អដោយក្បាច់ត្របកឈូកពណ៌មាស តំណាងឱ្យភាពសំបូររុងរឿងនៃសិល្បៈវប្បធម៌ និងប្រពៃណីនៃទឹកដីខេត្តបាត់ដំបង
- កួរស្រូវរាងរង្វង់មូលពណ៌មាសជួបគ្នានៅខាងចុង តំណាងឱ្យភោគផលកសិកម្មរបស់ខេត្តបាត់ដំបង ជាពិសេសដំណាំស្រូវដែលមានភាពល្បីល្បាញជាខេត្តជង្រុកស្រូវ និងការរួបរួមសាមគ្គីនៃប្រជាពលរដ្ឋខេត្តបាត់ដំបង
- គ្រឿងចក្រពណ៌មាស តំណាងឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចលើវិស័យឧស្សាហកម្ម ថាមពលអគ្គិសនី
- ខ្សែបូរុំព័ទ្ធកួរស្រូវមានពណ៌ខៀវក្រហម តំណាងឱ្យអត្តសញ្ញាណជាតិខ្មែរ ដែលមានខេត្តបាត់ដំបងជាចំណែកនៃទឹកដីព្រះរាជាណាចក្រកម្ពុជា
- ផ្ទៃខាងក្នុងពណ៌ផ្ទៃមេឃ៖ តំណាងឱ្យភាពស្រស់បំព្រងនៃទឹកដី ធម្មជាតិ បរិស្ថានល្អនៃទឹកដីខេត្តបាត់ដំបង
- ធ្នូតពណ៌សនៅពីក្រោមជើងពាន៖ តំណាងឱ្យព្រះធរណី ការគ្រប់គ្រងទឹកដី ខ័ណ្ឌសីមារបស់ខេត្តបាត់ដំបង។

**ប្រការ ៣.-**

និមិត្តសញ្ញាខេត្តបាត់ដំបងត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តបាត់ដំបង
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ-ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តបាត់ដំបង និងគណៈអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥ កើត ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃការប្រកាសលេខ ៧០៣៩ ប្រ.ក

ចុះថ្ងៃ ច័ន្ទ ៨ រោច ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ត្រូវនឹងថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៨

ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តបាត់ដំបង

## និមិត្តសញ្ញាខេត្តបាត់ដំបង

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ៧០៣៧ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបន្ទាយមានជ័យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តបន្ទាយមានជ័យជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តបន្ទាយមានជ័យមានរាង ខ្នាត និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងពងក្រពើ
- មានទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្ដោយ
- អមសងខាងក្នុងរង្វង់ដោយកួរស្រូវពណ៌លឿងទុំព័ទ្ធជាស្នែងក្របី រុំដោយបូដែលមានពណ៌ក្រហម និងផ្ទៃពណ៌ខៀវ
- នៅចំកណ្ដាលមានរូបចម្លាក់ព្រះអវលោកិតេស្វរៈដែលមានព្រះហស្ត៣២ ឈរលើកងចក្រ៧កាំ មានចារឹកអក្សរ "អវលោកិតេស្វរៈ" ពណ៌លឿង
- ផ្នែកខាងក្រោមមានបូពណ៌ខៀវលើ-ក្រោម និងចំកណ្ដាលផ្ទៃពណ៌ក្រហមមានអក្សរ "ខេត្តបន្ទាយ-មានជ័យ" ពណ៌ស
- អវលោកិតេស្វរៈ៖ ជាអ្នកជំក្នុងការប្រមើលមើល ឬពិនិត្យមើលសេចក្ដីសុខទុក្ខ និងចរិយារបស់សត្វលោក
- ព្រះហស្ត៣២៖ តំណាងឱ្យការកសាងព្រះបារមីរបស់ព្រះពោធិ៍សាត់ ដើម្បីសម្រេចបាននូវសម្មា-សម្ពោធិញ្ញាណ ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ
- កួរស្រូវពណ៌លឿងទុំ៖ តំណាងឱ្យផលិតផលកសិកម្ម ទទួលបានពីការប្រកបមុខរបរផ្អែកលើវិស័យកសិកម្ម ដោយប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យចំនួនប្រមាណ៨៥%ជាប្រជាកសិករ
- កងចក្រមានកាំប្រាំពីរ៖ តំណាងឱ្យពេងចក្រ សហគ្រាសដែលជាសក្ដានុពលនាពេលបច្ចុប្បន្ន និងទៅអនាគត កើតមានឡើងក្នុងទឹកដីខេត្តបន្ទាយមានជ័យ ដែលផលិតផលកសិកម្មភាគច្រើនកើតឡើងពីដំណាំកសិឧស្សាហកម្ម ដូចជា ដំណាំដំឡូង ពោត សណ្ដែក ល្ហុងប្រេង ដើមប្រេងខ្យល់ និងកៅស៊ូ ។ល។ លក្ខណៈពិសេសមួយទៀត គឺតំណាងឱ្យថ្ងៃជ័យជំនះជាប្រវត្តិសាស្ត្រ ថ្ងៃ ៧មករា ១៩៧៩។

**ប្រការ ៣.-**

និមិត្តសញ្ញាខេត្តបន្ទាយមានជ័យត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។ ៸

**ប្រការ ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ-ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ និងគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ស័ក ព.ស.២៥៦[illegible]

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃការប្រកាសលេខ ២១៣៧ ប្រក
ចុះថ្ងៃ ព្រហ ៨កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ត្រូវនឹងថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០១៨
ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តបន្ទាយមានជ័យ

# និមិត្តសញ្ញាខេត្តបន្ទាយមានជ័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៧០៣៨ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តឧត្តរមានជ័យ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តឧត្តរមានជ័យជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តឧត្តរមានជ័យមានរាង ខ្នាត និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្តោយ
- ព្រះលោកេស្វរៈជាអវតារព្រះវិស្ណុ៖ តំណាងឱ្យសេចក្តីសុខ ការបង្រួបបង្រួមសាសនា គ្មានជម្លោះសាសនា ឬជម្លោះផ្សេងៗកើតឡើង មានព្រះវិស្ណុនៅទីណាទីនោះនឹងមានសេចក្តីសុខយ៉ាងបរិបូណ៌
- កងចក្រ៖ តំណាងរដ្ឋបាលគ្រប់គ្រងដែនដី អំណាចគ្រប់គ្រងដ៏មានបារមី កំចាត់អំពើអាក្រក់
- គម្ពីរវេទ៖ តំណាងឱ្យការប្រកាន់គោលច្បាប់ជាធំ ពិសេសច្បាប់រដ្ឋធម្មនុញ្ញដែលជាច្បាប់គោល
- ដំបងមោងកស៖ តំណាងឱ្យវិស័យការពារជាតិ មានកងកម្លាំងប្រដាប់អាវុធដ៏រឹងមាំរបស់ជាតិ
- ព្រះពុទ្ធ៖ តំណាងឱ្យការគោរពព្រះពុទ្ធសាសនា ដែលជាសាសនាតែមួយរបស់ជាតិ
- តុមកំបោរ ឬថូទឹក៖ តំណាងឱ្យវិស័យសុខាភិបាល មានការព្យាបាលដ៏ស័ក្តិសិទ្ធនាំឱ្យចាកផុតទុក្ខទាំងពួង
- ផែនដី៖ តំណាងឱ្យវិស័យបរិស្ថាន ដែលផ្តល់នូវភាពអនុគ្រោះគ្រប់យ៉ាងដល់ជីវិតរស់នៅ
- ផ្កាឈូក៖ តំណាងឱ្យវិស័យអប់រំ សិក្សាធិការ ការបណ្តុះបណ្តាលធនធានមនុស្សល្អសម្រាប់សង្គម
- ខ្យងស័ង្ខ៖ តំណាងឱ្យប្រពៃណី ទំនៀមទំលាប់ដ៏ល្អផូរផង់ ឥតខ្ចោះរបស់ជនជាតិខ្មែរ។

**ប្រការ ៣.-**

និមិត្តសញ្ញាខេត្តឧត្តរមានជ័យត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖
- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តឧត្តរមានជ័យ
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ និងគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃការប្រកាសលេខ...២០៣៨/ប្រក

ចុះថ្ងៃ...ចន្ទ ៤ រោច... ខែ...ពិសាខ... ឆ្នាំ...ច សំរឹទ្ធិ...ស័ក ព.ស ២៥៦២...

ត្រូវនឹងថ្ងៃទី...០៣... ខែ...ឧសភា... ឆ្នាំ២០១៨

ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តឧត្តរមានជ័យ

ខេត្តឧត្តរមានជ័យ

# និមិត្តសញ្ញាខេត្តឧត្តរមានជ័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ២០៤០ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តក្រចេះ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តក្រចេះ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តក្រចេះជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តក្រចេះមានរាង ខ្នាត និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានទទឹងស្មើនឹង ២ ភាគ ៣ នៃបណ្តោយ
- ទម្រង់រួម៖ រាងត្របកឈូកតំណាងឱ្យអត្តសញ្ញាណជាតិ និងជាប្រទេសគោរពព្រះពុទ្ធសាសនា
- គ្រុឌ៖ តំណាងឱ្យសភាវៈល្អ គ្រប់គ្រងដែនដី ក្លាហាន ការពារធម្មជាតិ និងខ្យល់
- នាគ៖ តំណាងឱ្យសភាវៈល្អ ភាពត្រជាក់ត្រជុំ គ្រប់គ្រងព្រះគង្គា ព្រះភិរុណ និងព្រះអគ្គី
- បល្ល័ង្គ៖ តំណាងឱ្យអរិយធម៌ជាតិ តាមរចនាបថភ្នំដា ក្បាច់ត្របកឈូកអង្គរធែក
- ក្បាច់រចនា៖ តំណាងឱ្យវប្បធម៌ខ្មែរដ៏រុងរឿង
- ពណ៌មាស៖ តំណាងឱ្យភាពសំបូររុងរឿង(សុវណ្ណភូមិ)
- ពណ៌ដីលែង៖ តំណាងឱ្យជាតុថ្មរឹងមាំ
- ពណ៌បៃតង៖ តំណាងឱ្យការអភិវឌ្ឍ។

**ប្រការ ៣.-**

និមិត្តសញ្ញាខេត្តក្រចេះត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តក្រចេះ
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

**ប្រការ ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការ-ដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តក្រចេះ និងគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃការប្រកាសលេខ......២០៤០ ប្រក.....**

**ចុះថ្ងៃ......ចន្ទ ១៤ រោច...... ខែ......ភទ្របទ...... ឆ្នាំ......ច សំរឹទ្ធិ......ស័ក ព.ស ២៥៦២......**

**ត្រូវនឹងថ្ងៃទី......០៨...... ខែ......តុលា...... ឆ្នាំ២០១៨**

**ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តក្រចេះ**




## និមិត្តសញ្ញាខេត្តក្រចេះ